ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

សេចក្តីកែតម្រូវ : *រាជកិច្ចលេខ ៥៧ ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០១២ នៅទំព័រ ត បន្ទាត់ទី ៧ ដែលសរសេរថា : ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម **ប្រធានរដ្ឋសភា** នីតិកាលទី ៣..... សូមកែតម្រូវ : ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម **ប្រធានព្រឹទ្ធសភា** នីតិកាលទី ៣..... វិញ ។ សូមអរគុណ !*

០៣-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧០១ ស្តីពី ការតែងតាំង ជាទីប្រឹក្សា និង ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ ចំនួន ០៣ រូប ៥៨០៤

០៣-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧០២ ស្តីពី ការតែងតាំងលោកស្រី **បេខ ម៉ូរ៉ាត់** ជា ឧកញ៉ា ៥៨០៥

០៣-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧០៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ៦២ រូប ៥៨០៦

II~ក្រុមប្រឹក្សាធម្មនុញ្ញ

០១-៨-២០១២ -សេចក្តីសម្រេចលេខ ១២២/០០៣/២០១២ កបធ.ច ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ ៥៨០៨

III~រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៧-៨-២០១២ -អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៥៨១១

០៣-៨-២០១២ -អនុក្រឹត្យលេខ ៩៣២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៨១៣

០៣-៨-២០១២ -អនុក្រឹត្យលេខ ៩៣៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨១៤

០៣-៨-២០១២ -អនុក្រឹត្យលេខ ៩៣៤ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៨១៥

០៦-៨-២០១២ -អនុក្រឹត្យលេខ ៩៣៥ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៨១៧

០៦-៨-២០១២ -អនុក្រឹត្យលេខ ៩៣៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៨១៨

០៦-៨-២០១២ -អនុក្រឹត្យលេខ ៩៣៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៨១៩

០៦-៨-២០១២ -អនុក្រឹត្យលេខ ៩៣៨ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៥៨២០

០៦-៨-២០១២ -អនុក្រឹត្យលេខ ៩៣៩ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៨២១

០៧-៨-២០១២ -អនុក្រឹត្យលេខ ៩៤០ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៨២២
០៧-៨-២០១២ -អនុក្រឹត្យលេខ ៩៤១ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៨២៤
០៨-៨-២០១២ -អនុក្រឹត្យលេខ ៩៤២ អនក្រ.តត ស្ដីពី ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៥៨២៦

III~ការងារបណ្ដាក្រសួង

ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២០-៤-២០១១ -លិខិតបញ្ជាក់លេខ ២១៥៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម្រេក្លនឌើរ មេធៀរៀល អ៊ីមផត អិចផត** ៥៨២៨

២១-៤-២០១១ -លិខិតបញ្ជាក់លេខ ២១៧១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តាយឌូ ខនស្ត្រាក់សិន & ដេគរ អ៊ិនធីនារីឲ ឆាយណា** ៥៨៣០

២១-៤-២០១១ -លិខិតបញ្ជាក់លេខ ២១៧២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី.អ៊ី.ធី ឌីវេឡុបមេន គ្រុប** ៥៨៣២

២១-៤-២០១១ -លិខិតបញ្ជាក់លេខ ២១៧៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុខណ្ណា ខេមបូ ហ្វាម៉ាតូ** ៥៨៣៤

២១-៤-២០១១ -លិខិតបញ្ជាក់លេខ ២១៧៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឥន្ទ្រីពេជ្រ** ៥៨៣៦

២១-៤-២០១១ -លិខិតបញ្ជាក់លេខ ២១៨១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម ប៊ី យូ អ៊ិនវេស មេន គ្រុប** ៥៨៣៨

២១-៤-២០១១ -លិខិតបញ្ជាក់លេខ ២១៨២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីនឈ្វូឌ ៤ អ៊ិនធើណេ សិនណាល គ្រុប** ៥៨៤០

ព្រះរាជក្រឹត្យ

នស/រកត/០៤១២/៣០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រមុខរដ្ឋស្តីទី

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងជាទីប្រឹក្សា និងជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

ក- **ទីប្រឹក្សា** ចំនួន ០២ រូប :

១- ឯកឧត្តម **ផែង ព្រុំប៉ុំឡែន** មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម **ហែម សុវណ្ណារិទ្ធ** មានឋានៈស្មើ **រដ្ឋលេខាធិការ**

ខ- **ជំនួយការ** ចំនួន ០១ រូប :

១- ឯកឧត្តម **អ៊ុក សុថា** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា២ : លេខរៀងទី១ ផ្នែក ខ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៦៩ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៦៦. ១២០៥.៣០៥

លេខៈ ៦៧៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២
អគ្គលេ[illegible]ទីស្តីការរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៧០២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកស្រី បេង ម៉ូរ៉ាត់

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣១ល. ១២០៤.៧០៩

លេខៈ ៦៧៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៧១២/៧០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ៦២ រូប ដែលមានគុណបំណាច់

ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម ឡាយ ម៉ារីវ្វ
២- លោក ទូ ហាយ
៣- លោក គង់ សត្ថារិន
៤- លោក ផាន់ សុផល
៥- លោក ទូច ដាណារ៉ា
៦- លោក នឹម ពិសី
៧- លោក ច័ន្ទ សម្បត្តិ
៨- លោក កុយ រុំ
៩- លោក វ៉ា ម៉ាស៊ូតសាយ៉ាម
១០- លោក ឡុង សំអឿន
១១- លោក ជា ស៊ុយទ្រី
១២- លោក អ៊ុំ វណ្ណា
១៣- លោក ញ៉ែម បូរីម
១៤- លោក ស៊ីង សំអុល
១៥- លោក ខៀវ សំអឿន
១៦- ព្រះឧត្តមញាណ ជុំ វណ្ណា
១៧- ឯកឧត្តម សំ បូរ
១៨- ឯកឧត្តម ហួន សុផល
១៩- លោក ប៊ុតផន សុភារម្យ
២០- លោក ឃួយ បញ្ញា
២១- លោក ម៉ក់ សុកេទី
២២- លោក ហេង សំបូរ
២៣- លោក ជាប សុខ
២៤- លោក ប៊ុតផន សុភត្រា
២៥- លោក មេង យុយ
២៦- លោក ឈុន សំអូន
២៧- លោក អ៊ាង ភារៈ
២៨- លោក ខាត់ គីមយឿន
២៩- លោក វៀម វ៉ា
៣០- ព្រះតេជគុណ សៀក សុន
៣១- លោក ជុត សាម៉ុន
៣២- លោក ស៊ុ ហ៊ុង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោក ម៉ុន រ៉ៃ ២- លោក ហ៊ាន់ គីមស្រ៊ុន

គ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម សំ ឈីម ២- ឯកឧត្តម អ៊ិន រស្មីរិទ្ធី

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- លោក ចេវ ហាក់ ៥- លោក សិរិទ្ធ សុខហួន

២- លោក កុសល សុវណ្ណរតនៈ ៦- លោក អ៊ឹង សុងឃូ

៣- លោក ឆាយ ជោតនា ៧- លោក កុល សំអុល

៤- លោក ហ៊ិន ពុត្រា ៨- លោក កុល គីឡាវីរៈ

ង- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- លោក ជ្រួយ ជ្រៃ ៣- លោក ចេង ឡេង

២- លោក ឡោ តេងតេង ៤- លោក ញ៉ែម នេត

ច- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

១- លោក ជិន តូម៉ាក់

ឆ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- ព្រះសុធម្មវង្ស ចឹក ធុន ៦- លោក ឃុន សុខជា

២- ព្រះគ្រូចៅអធិការ វង្ស សំណាង ៧- លោក ហ៊ួន សំអាន

៣- លោក សូ វណ្ណធឿន ៨- លោក ហង្ស ផល្លា

៤- លោក ហ៊ាន វៃរឿន ៩- លោក ជាង ចន្ធី

៥- លោក ខេព ចូស៊ីបូ ១០- លោក ជាន់ ប៊ុនហុក

ជ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោក ហួរ ឆាយ ៣- លោក មុំ រិទ្ធី

២- លោក ប៊ុន ធឿន ៤- លោក ឈាន កើប

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំបន្ទាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣រក.១២០៥.៣១០

លេខ: ៦៧៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១២

អគ្គលេខាធិការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល លេខ: 2766
ថ្ងៃទី 06 ខែ 08 ឆ្នាំ 2012
ម៉ោង ...

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១៩៣/០០២/២០១២

ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១២

សេចក្តីសម្រេច

លេខ : ១២២/០០៣/២០១២ កបធ.ច

ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១២

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០២៦/០៧១២/ពស/ព.ន.វ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ របស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលបានអនុម័តយល់ព្រមចំនួន ៤៥ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល នាសម័យប្រជុំលើកទី១ នីតិកាលទី៣ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១២ វេលាម៉ោង ០៩ និង ៤៥ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សំណើរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការ

របៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដោយមានសំឡេងយល់ព្រម ៤៥ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល គឺស្របនឹងមាត្រា ១១៤ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ១ "អំពីការិយាល័យបណ្តោះអាសន្ន និងភារកិច្ច"** ដែលមាន ៣ ប្រការ គឺប្រការ ១ ដល់ប្រការ ៣ ស្របនឹងមាត្រា ១០៦ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ២ "អំពីសុពលភាពនៃអាណត្តិរបស់សមាជិកព្រឹទ្ធសភា"** ដែលមាន ២ ប្រការ គឺប្រការ ៤ និងប្រការ ៥ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៣ "អំពីប្រធាន អនុប្រធាន គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភា"** ដែលមាន ២១ ប្រការ គឺប្រការ ៦ ដល់ប្រការ ២៦ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៤ "អំពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា"** ដែលមាន ៤ ប្រការ គឺប្រការ ២៧ ដល់ប្រការ ៣០ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៥ "អំពីវិស្សមកាល"** ដែលមាន ១ ប្រការ គឺប្រការ ៣១ ធ្វើឡើងស្របនឹងមាត្រា ១០៥ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ៦ "អំពីការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានាំចូល"** ដែលមាន ៤ ប្រការ គឺប្រការ ៣២ ដល់ប្រការ ៣៥ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៧ "អំពីរបៀបវារៈប្រជុំ"** ដែលមាន ២ ប្រការ គឺប្រការ ៣៦ និងប្រការ ៣៧ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៨ "អំពីរបៀបប្រជុំ"** ដែលមាន ១៩ ប្រការ គឺប្រការ ៣៨ ដល់ប្រការ ៥៦ ធ្វើឡើងស្របនឹងមាត្រា ១១០ថ្មី និងមាត្រា ១១១ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ៩ "អំពីការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានាំចូលក្នុងពេលប្រជុំព្រឹទ្ធសភា"** ដែលមាន ៤ ប្រការ គឺប្រការ ៥៧ ដល់ប្រការ ៦០ ធ្វើឡើងស្របនឹងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ១០ "អំពីការបញ្ចេញមតិ"** ដែលមាន ៧ ប្រការ គឺប្រការ ៦១ ដល់ ប្រការ ៦៧ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ១១ "អំពីការរក្សាសេចក្តីស្ងប់ស្ងាត់ក្នុងពេលប្រជុំ"** ដែលមាន ៣ ប្រការ គឺប្រការ ៦៨ ដល់ប្រការ ៧០ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា **ជំពូកទី ១២ "អំពីការឈប់ ឬការខានមកប្រជុំ"** ដែលមាន ៥ ប្រការ គឺប្រការ ៧១ ដល់ប្រការ ៧៥ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ១៣ "អំពីវិន័យក្នុងព្រឹទ្ធសភា"** ដែលមាន ៦ ប្រការ គឺប្រការ ៧៦ ដល់ប្រការ ៨១ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ១៤ "អំពីការសុំកែប្រែបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា"** ដែលមាន ២ ប្រការ គឺប្រការ ៨២ និងប្រការ ៨៣ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ១៥ "អំពីអវសានប្បញ្ញត្តិ"** ដែលមាន ១ ប្រការ គឺប្រការ ៨៤ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា បទប្បញ្ញត្តិទាំងអស់នៃប្រការទាំង ៨៤ នៅក្នុងជំពូកទាំង ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១.- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តនាសម័យប្រជុំលើកទី១ នីតិកាលទី៣ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១២ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១២

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

Raw-186

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..១១៨...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករនាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន២ ០០០ ០០០ ០០០រៀល(ពីរពាន់លានរៀលគត់) ពីជំពូក ០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦០(ការទិញ) ជូនក្រសួងមហាផ្ទៃ(ផ្នែកសន្តិសុខសាធារណៈ) សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់បំណុលជូនក្រុមហ៊ុនសូគីម៉ិចថ្លៃទិញប្រេងឥន្ធនៈបន្ថែមបង្គ្រប់សេចក្តីត្រូវការប្រើប្រាស់ឆ្នាំ២០១១ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៧ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩៣២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប ដែលបានផ្តល់ថវិកា ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង និងអគារបណ្ណាល័យ០១ខ្នង ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនដល់វិទ្យាល័យសម្តេចក្រុមព្រះអង្គរនាប ស្ថិតនៅឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ:

១-ឯកឧត្តម ខៀវ ភាញារិទ្ធ ថវិកាចំនួន ១០.០០០ ដុល្លារ

២-លោក អ៊ីុង សុត និងអ្នកស្រី សម ចាន់ហម ថវិកាចំនួន ១១.៥៩៤ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

-អ្នកស្រី គីម ហួរ ថវិកាចំនួន ៥.០០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:៧៣៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនជនជាតិឥណ្ឌូនេស៊ី ចំនួន០២រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការរវាងកងទ័ពជើងគោក នៃប្រទេសទាំងពីរ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:
-វរសេនីយ៍ឯក IGNATIUS YOGO TRIYONO អនុព័ន្ធយោធានៃសាធារណរដ្ឋឥណ្ឌូនេស៊ី

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សប្បទិ្ធ:
-លោក MATH ALMIN ជំនួយការ អនុព័ន្ធយោធានៃសាធារណរដ្ឋឥណ្ឌូនេស៊ី

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ៧ ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩៣៤-អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូននាយទាហាននៃសាធារណរដ្ឋឥណ្ឌូនេស៊ី ចំនួន ០៦រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការរវាងកងទ័ពជើងគោកនៃប្រទេសទាំងពីរ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ:

-ឧត្តមសេនីយ៍ទោ DEDI KUSNADI THAMIM ជំនួយការផ្ទាល់ឯកឧត្តម មេបញ្ជាការកងទ័ពជើងគោកជាតិឥណ្ឌូនេស៊ី ទទួលបន្ទុកប្រតិបត្តិការសឹក

ខ-មេដាយសហមេត្រី ថ្នាក់ សេនា:

-វរសេនីយ៍ឯក IRWANSYAH នាយទាហានជាន់ខ្ពស់ ទទួលបន្ទុកកិច្ចសហប្រតិបត្តិការយោធាអន្តរជាតិ នៃនាយកដ្ឋានប្រតិបត្តិការសឹក កងទ័ពជើងគោកជាតិ ឥណ្ឌូនេស៊ី

គ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ:

១-វរសេនីយ៍ទោ BONI C. PARDEDE នាយទាហានមធ្យម ទទួលបន្ទុកកិច្ចសហប្រតិបត្តិការទ្វេភាគី នៃនាយកដ្ឋានប្រតិបត្តិការសឹក កងទ័ពជើងគោកជាតិ ឥណ្ឌូនេស៊ី

២-វរសេនីយ៍ទោ ROBERTUS DONATUS NDONA នាយទាហានមធ្យម ទទួលបន្ទុកបណ្តុះបណ្តាល និងហ្វឹកហ្វឺន នៃនាយកដ្ឋានបុគ្គលិក កងទ័ពជើងគោកជាតិ ឥណ្ឌូនេស៊ី

៣-វរសេនីយ៍ទោ ROBERTSON ISMAIL នាយទាហានមធ្យម ផ្នែកចារកម្ម នៃនាយកដ្ឋានសន្តិសុខ កងទ័ពជើងគោកជាតិ ឥណ្ឌូនេស៊ី

៤-វរសេនីយ៍ត្រី PERRY SANDHI SITOMPUL នាយទាហាន ទទួលបន្ទុកកិច្ចសហប្រតិបត្តិការទ្វេភាគីនិងកិច្ចសហប្រតិបត្តិការយោធាអន្តរជាតិ នៃនាយកដ្ឋានប្រតិបត្តិការសឹក កងទ័ពជើងគោកជាតិ ឥណ្ឌូនេស៊ី

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៣៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនដៃគូសន្តិសុខសហរដ្ឋអាមេរិក និងប្រទេសអូស្ត្រាលី ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយសាងសង់អគារថ្មីមួយខ្នង និងជួសជុលអគារចាស់មួយខ្នង ព្រមទាំងបំពាក់គ្រឿងបរិក្ខារ និងសម្ភារៈបញ្ជូនសារជូនទីបញ្ជាការជួរមុខរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ស្ថិតក្នុងបរិវេណ មូលដ្ឋានសមុទ្ររាម កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ:

១-វរសេនីយ៍ឯក **ម៉ាក អឹម ជីឡេត្ត** (Mark M. Gillette) សេនានុព័ន្ធយោធាសហរដ្ឋអាមេរិក

២-វរសេនីយ៍ឯក **ឡេវីស ខយ** (Lewis Coyle) សេនានុព័ន្ធយោធាអូស្ត្រាលី

ខ-មេដាយសហមេត្រី ថ្នាក់ សេនា:

១-វរសេនីយ៍ទោ **គ្រីស្ទីន អេ មីនស៍** (Kristin A. Means) ប្រធានការិយាល័យសហប្រតិបត្តិការយោធាស្ថានទូតសហរដ្ឋអាមេរិក

២-លោក **ឡែន ម៉ាក់ អ៊ីននីស** (Lance Mc Innis) តំណាង Jiatf សហរដ្ឋអាមេរិក

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៧ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៣៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងផ្តល់ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមក្នុងការកសាងព្រះវិហារ អគារសិក្សានិងសមិទ្ធផលផ្សេងៗទៀត នៅ វត្តសិរីសុវណ្ណ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ:

- លោក **យ៉ង់ សៅវុឌ្ឍី** អនុប្រធានមន្ទីរសង្គមកិច្ចខេត្ត និងជាក្រុមការងារចុះជួយឃុំរលាប្អៀរ បានចំណាយអស់ថវិកាចំនួន ១៦.៥០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

១-ព្រះតេជគុណ	**សោម ចាន់ធឿន**	ព្រះចៅអធិការវត្ត សិរីសុវណ្ណ	បច្ច័យចំនួន ៥.២៥០ ដុល្លារ
២-ឧបាសក	**ម៉ៅ សន**	អាចារ្យវត្ត	ថវិកាចំនួន ៥.១៥០ ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិ:

១-លោក	**លី គឿង**	សប្បុរសជននៅខេត្តកំពង់ឆ្នាំង	ថវិកាចំនួន ៣.៥០០ ដុល្លារ
២-លោក	**ម៉ម សឿន**	ប្រធានគណៈកម្មការវត្ត	ថវិកាចំនួន ២.៥០០ ដុល្លារ
៣-លោក	**សេន សារ៉េត**	គណៈកម្មការវត្ត	ថវិកាចំនួន ២.៥០០ ដុល្លារ
៤-លោក	**ហ៊ុយ ទីន**	អនុប្រធានគណៈកម្មការវត្ត	ថវិកាចំនួន ២.២៥០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង[illegible]គណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃ[illegible] ខែ [illegible] ឆ្នាំ ២០១២

[illegible]នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៣៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ចំនួន ០៤គ្រឿង ជូនទីប្រឹក្សាបច្ចេកទេសចិន ចំនួន ០៤រូប ដែលមានស្នាដៃល្អក្នុងការសាងសង់ផ្លូវជាតិលេខ៦២ ពីខេត្តកំពង់ធំ ដល់ទីរួមខេត្តព្រះវិហារ សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ

1-	Mr.	XIN GUOSHUN	Deputy General of SCGC
2-	Mr.	HE LUESA	Deputy General Manager of SCGC
3-	Mr.	ZHANG CHAOYING	Chief Engineer of GWCS

ខ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ

-	Mr.	ZONG QINGHENG	Consultant Group Leader GWCS

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៣៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានតែងតាំងមុខងារ នាយទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ទោ **ម៉ៅ សុវណ្ណ** អត្តលេខ ០០០២៧៥ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២-ឧត្តមសេនីយ៍ទោ **ជា កែវ** អត្តលេខ ០០៤៣៥១ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៣៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក ZHENG JINHUA Project Manager of NR62 សញ្ជាតិចិន ដែលមានស្នាដៃល្អក្នុងការសាងសង់ផ្លូវជាតិ លេខ៦២ ផ្នែកខាងត្បូង ពីខេត្តកំពង់ធំ ដល់ទីរួមខេត្តព្រះវិហារ ប្រវែង ១២៨ គ.ម រហូតដល់ចប់ជាស្ថាពរ ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
